ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម

១៣-៧-២០០១ -ព្រះរាជក្រម នស/រកម/០៧០១/០៩ ច្បាប់ស្តីពីការគ្រប់គ្រងធ្វើអាជីវកម្មធនធានរ៉ែ ១៧៣០

### ២_ព្រះរាជក្រឹត្យ

១១-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២២៥ តែងតាំងឯកឧត្តម ម៉ិន ឈិន ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ១៧៤៨
១១-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២២៧ តែងតាំងលោក ខូច ឆៀងស៊ាង ជាឧកញ៉ា ១៧៤៩
១១-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២២៨ តែងតាំងឯកឧត្តម សុខ សារុធ ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ១៧៥០
១១-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២២៩ តែងតាំងលោក តែ តាំងប៉ោ ជាឧកញ៉ា ១៧៥១
១១-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣១ ស្តីពីការបង្កើតសញ្ញាសក្តិ និងឯកសណ្ឋានសំរាប់សំគាល់សមាជិកសហជីពព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ១៧៥២
១៣-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣២ តែងតាំងឯកឧត្តម ឡោក់ ផល្លី ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី ១៧៦៨

## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

០៩-៧-២០០១ -អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៧៦៨
០៩-៧-២០០១ -អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៧៧១
០៩-៧-២០០១ -អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ១៧៧៣

១២-៧-២០០១ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ១៧៩០

## ២-សេចក្តីសំរេច

០៦-៧-២០០១ -សេចក្តីសំរេចលេខ ៣៨ សសរ. ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍ រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់នៃការទាមទារអះអាង ដែនសមុទ្រស៊ីគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា-ថៃ ១៧៩២

១២-៧-២០០១ -សេចក្តីសំរេចលេខ ៣៩ សសរ. ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ថាមពល កកើតឡើងវិញ និងបច្ចេកវិទ្យាថាមពលកម្ពុជា-ជប៉ុន ១៧៩៦

១៤-៧-២០០១ -សេចក្តីសំរេចលេខ ៤០ សសរ. ស្តីពីការបង្កើតគណៈកម្មាការស្រាវជ្រាវ បាតុភាពផ្ទុះគ្រាប់បែកនៅសណ្ឋាគារហុងកុង និងសណ្ឋាគារ ម៉ាន អ៊ី (ហៅ ពេញចិត្ត) ១៧៩៩

# III-ភាគទារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស

១០-៧-២០០១ -ប្រកាសលេខ ៤៧២ សហវ.ទវ ស្តីពីការបង្កើតក្រុមការងារចំរុះអន្តរក្រសួង ដើម្បីពិនិត្យកិច្ចសន្យាលក់ ឬជួលចលនវត្ថុ ឬអចលនវត្ថុ នៅក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់ និងប្រមូលចំណូលបង់ចូលថវិការដ្ឋ ១៨០១

១២-៧-២០០១ -ប្រកាសលេខ ៤៧៩ សហវ. ប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាននៅផ្នែកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ១៨០៣

## ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

១២-៧-២០០១ -ប្រកាសលេខ ៤៤១ ឧរថ.ឧតស.ប្រក អនុញ្ញាតឱ្យលោក គង់ សិរីភា ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្ម កែច្នៃស្រា "សេដ្ឋីបុត្រ" ១៨០៥

## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងព័ត៌មាន

### ប្រកាស

០៩-៧-២០០១ -ប្រកាសលេខ ១៩៣/០១ ពម.ប្រក អនុញ្ញាតឱ្យសារព័ត៌មាន "អ្នកប្រយុទ្ធ" បន្តការបោះពុម្ពផ្សាយ ១៨០៦

១០-០៧-២០០១ -ប្រកាសលេខ ១៩៤/០១ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨០៧

១០-០៧-២០០១ -ប្រកាសលេខ ១៩៥/០១ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨០៨

**៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**ប្រកាស**

១៣-០៧-២០០១ -ប្រកាសលេខ ៥៣៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រៃធំ ស្ថិតនៅក្នុងឃុំពេជសារ ស្រុកកោះអណ្តែត ខេត្តតាកែវ ១៨០៩

១៣-០៧-២០០១ -ប្រកាសលេខ ៥៣៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន "មង្គលបពិត្រ" ស្ថិតនៅក្នុង ឃុំផុង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ១៨១០

១៣-០៧-២០០១ -ប្រកាសលេខ ៥៣៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "ព្រៃតាសក់" ស្ថិតក្នុងឃុំ ត្នោតចុងស្រង់ ស្រុកបន្ទាយមាស ខេត្តកំពត ១៨១១

១៣-០៧-២០០១ -ប្រកាសលេខ ៥៣៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "ស្វាយតាឆាន់" ស្ថិតនៅក្នុងឃុំ ព្រែករំដេង ស្រុក ស្រីសន្ធរ ខេត្តកំពង់ចាម ១៨១២

**៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ**

**ប្រកាស**

១០-០៧-២០០១ -ប្រកាសលេខ ១០៣ ប្រក.កអជ ស្តីពីការបង្កើតគណៈកម្មាធិការវាយតំលៃសំរាប់ផ្គត់ផ្គង់សំភារៈ ដល់ការអនុវត្តន៍គំរោងអភិវឌ្ឍន៍សហគមន៍មូលដ្ឋានជនបទក្នុងក្របខ័ណ្ឌ នៃមូលនិធិឯនន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម ១៨១៣

**៦-ទីស្តីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌**

**ប្រកាស**

១២-០៧-២០០១ -ប្រកាសលេខ ១១៩ ប្រក.បបប ២០០១ ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨១៥

**៧-ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**

**សេចក្តីសំរេច**

០៩-០៧-២០០១ -សេចក្តីសំរេចលេខ ១៩៤ កធស្កសរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ចំការទំពាំងបាយជូរ" ស្ថិតនៅភូមិអង្គរខ្មៅថ្មី ឃុំតយម៉ែង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ១៨១៦

| | | |
|---|---|---|
| ១១-០៧-២០០១ | -សេចក្តីសំរេចលេខ ១៩៧ កធស.សរ ស្តីពីការទទួលស្គាល់អារាមវត្តចេតិយ៍ទន្ទឹមលើកំពូលភ្នំព្រះរាជទ្រព្យមកស្ថាក់នៅទីតាំងថ្មី លើដីទួលអតីតវត្តទួលវិហារកោះអណ្តែត | ១៨១៧ |
| ១២-០៧-២០០១ | -សេចក្តីសំរេចលេខ ១៩៨ កធស.សរ ប្រកាសបិទចោលទាំងស្រុងចំពោះសេចក្តីប្រកាសលេខ ១៧៩.៩៨ កធស ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ | ១៨១៨ |
| ១២-០៧-២០០១ | -សេចក្តីសំរេចលេខ ១៩៩ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "បល្ល័ង្គ" ស្ថិតនៅភូមិ បល្ល័ង្គ ឃុំ ដីរជាន់ខ្លា ស្រុកស្ទឹងសែន ខេត្ត កំពង់ធំ | ១៨១៩ |
| ១២-០៧-២០០១ | -សេចក្តីសំរេចលេខ ២០០ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ក្រុមជំនុំភូមិត្រពាំងតាកែវ" ស្ថិតនៅភូមិតាកែវ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង | ១៨២០ |
| ១២-០៧-២០០១ | -សេចក្តីសំរេចលេខ ២០១ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ភូមិចេកមួយស្នង" ស្ថិតនៅភូមិចេកមួយស្នង ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ១៨២១ |
| ១៣-០៧-២០០១ | -សេចក្តីសំរេចលេខ ២០២ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ភូមិប្រាសាទ" ស្ថិតនៅភូមិ ប្រាសាទ ឃុំ សាន់គរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ | ១៨២២ |
| ១៣-០៧-២០០១ | -សេចក្តីសំរេចលេខ ២០៣ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ភូមិបាជ័យ" ស្ថិតនៅភូមិបាជ័យ ឃុំ សណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ១៨២៣ |
| ១៣-០៧-២០០១ | -សេចក្តីសំរេចលេខ ២០៤ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ "ភូមិសាលាពពេល" ស្ថិតនៅភូមិ សាលាពពេល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ | ១៨២៤ |

# ព្រះរាជក្រម

នស/រកម/០៧០១/០៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និងពីរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៕

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ N.T.

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា ។ លើកលែងតែប្រតិបត្តិការប្រេងកាតនិងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

មាត្រា ២.-

ធនធានរ៉ែទាំងអស់ដែលបិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រ ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ ។

មាត្រា ៣.-

ធនធានរ៉ែគឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័នដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាតនិងឧស្ម័ន ។

ប្រតិបត្តិការធនធានរ៉ែគឺជាការធ្វើសកម្មភាព បុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

បុរេសនាគឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

ការស្វែងរុករកគឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្ម។ល។

តាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការជីកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ។

អាជីវកម្មធនធានរ៉ែគឺជាប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីដម្រេករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម ។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហធាតុមានតម្លៃត្បូងថ្មមានតម្លៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ។

## ជំពូកទី ២
## អាជ្ញាប័ណ្ណធនធានរ៉ែ

មាត្រា ៤.-

អាជ្ញាប័ណ្ណធនធានរ៉ែគឺជាលិខិតអនុញ្ញាតដែលផ្តល់នូវសិទ្ធិឱ្យទៅសម្បទានិកដោយស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ ។

មាត្រា ៥.-

គ្មានរូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយលើកលែងតែម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លីដែលជាឯកជនអាចប្រើប្រាស់ ក្រួស ខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដែនដីធ្លីជាកម្មសិទ្ធិដើម្បីធ្វើអាជីវកម្មនោះទេ ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋឱ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ ។ល។

មាត្រា ៦.-

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចនឹងទទួលអាជ្ញាប័ណ្ណធនធានរ៉ែបានទៅតាមការពិនិត្យពិច័យនៅលើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្ម ។

មាត្រា ៧.-

មុននឹងចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជនដើម្បីធ្វើការស្វែងរុករកនិងជីកយករ៉ែ សម្បទានិកត្រូវមានការព្រមព្រៀងជាលាយល័ក្ខអក្សរជាមួយម្ចាស់កម្មសិទ្ធិដីធ្លីស្តីពីការមិនជ្រៀតជ្រែក មិនប៉ះពាល់ដល់ទ្រព្យសម្បត្តិនិងការងារព្រមទាំងធ្វើការទូទាត់សងលើការខូចខាតដែលកើតមាននៅលើផ្ទៃដី ដែលបណ្តាលមកពីសកម្មភាពប្រតិបត្តិការធនធានរ៉ែ ។

មុននឹងចូលក្នុងតំបន់ដែលជាកម្មសិទ្ធិរបស់រដ្ឋដែលកំណត់ថាជាតំបន់ការពារ តំបន់បំរុងទុក ឬតំបន់ហាមឃាត់ដើម្បីស្វែងរុករកនិងជីកយករ៉ែ សម្បទានិកត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នអន្តរក្រសួងដែលមានតួនាទីគ្រប់គ្រងលើតំបន់នោះ ។

មាត្រា ៨.-

ការធ្វើបុរេសនា ការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅលើដីជាកម្មសិទ្ធិរដ្ឋដែលបានកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ តំបន់បេតិកភ័ណ្ឌជាតិត្រូវហាមឃាត់ ។

មាត្រា ៩.-

មិនអាចចេញអាជ្ញាប័ណ្ណធនធានរ៉ែឱ្យត្រួតគ្នានៅតំបន់ណាមួយដែលឋិតនៅក្រោមការកាន់កាប់របស់សម្បទានិកមួយផ្សេងទៀតរួចទៅហើយដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសម្បទានិកមុន ឬការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ដែលបញ្ជាក់ថាសិទ្ធិផ្តាច់មុខរបស់សម្បទានិកមុនពុំមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ឡើយ ។ល។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែគ្រប់គ្រង ត្រូវតពិនិត្យរាល់ប្រតិបត្តិការធនធានរ៉ែ ដើម្បីឱ្យការអនុវត្តន៍បទប្បញ្ញត្តិនិងនីតិវិធីទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែរក្សាទុកសំណុំឯកសារនិងកំណត់ត្រាក្នុងបញ្ជីឯកសារចំពោះរាល់អាជ្ញាប័ណ្ណដែលចេញឱ្យព្រមទាំងឯកសារដែលពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ។

## ជំពូកទី ៣
## ប្រភេទនៃអាជ្ញាប័ណ្ណធនធានរ៉ែ

មាត្រា ១១.-

អាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានរៀបចំជាប្រាំមួយប្រភេទ ដើម្បីសម្រួលដល់អ្នកដាក់ពាក្យសុំក្នុងគោលដៅសម្រួលការគ្រប់គ្រងលើការងារស្វែងរុករកនិងធ្វើអាជីវកម្មធន-ធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព ។

**១-អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ** អាចផ្តល់ឱ្យចំពោះតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ក្នុងគោលបំណងអនុវត្តការងារស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែដោយប្រើប្រាស់ឧបករណ៍សម្ភារៈសាមញ្ញ ដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួនឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី ៧ (ប្រាំពីរ) នាក់ ។

សិប្បកម្មធនធានរ៉ែអាចធ្វើការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែបានចំពោះតែធនធានរ៉ែដែលរកឃើញក្នុងសភាពជាធនធានរ៉ែរាយប៉ាយនៅក្នុងដីល្បាប់ ខ្សាច់ ក្រួសសិលា ក្នុងផ្ទៃដីកំណត់មួយមានទំហំមិនលើសពី ១ (មួយ) ហិកតា និងជម្រៅមិនហួសពី ៥ (ប្រាំ) ម៉ែត្រ ។

**២-អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម** អាចផ្តល់ឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ ក្នុងបំណងអនុវត្តការងារស្វែងរុករក ធ្វើអាជីវកម្មធនធានរ៉ែសំណង់និងធនធានរ៉ែឧស្សាហកម្មណាមួយបម្រើឱ្យការសាងសង់ ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃ ហើយជីកយកពីអណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម ។ល។

ធនធានរ៉ែសំណង់និងធនធានរ៉ែឧស្សាហកម្មមានជាអាទិ៍ ខ្សាច់ ក្រួស ថ្មសំណង់ ឡាតេរីត ដីឥដ្ឋ ដីឥដ្ឋធ្វើស៊ីម៉ង់ត៍ ផូស្វីលផ្កាថ្ម ហ្វូស្វរីត ថ្មកំបោរ ដូឡូមីត ថ្មម៉ាប កៅឡាំង ប៉ាហ្គោឌីត អំបិល ប៉ូតាស ម្នាងសិលា ត្បូងភក់ ត្បូងថ្ម ខ្សាច់ទីតាន ខ្សាច់ស៊ីលីស ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលប្រើប្រាស់ក្នុងគោលដៅដូចគ្នា ។

**៣-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ** អាចផ្តល់ឱ្យដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ក្នុងបំណងស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសំអាង ។

ត្បូងថ្មមានតម្លៃមានជាអាទិ៍ ពេជ្រ ត្បូងទទឹម កណ្តៀង មរកត និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

ត្បូងថ្មពាក់កណ្តាលមានតម្លៃមានជាអាទិ៍ សៀកកុន អាមេទីស តូប៉ាស និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

ថ្មសំអាងគឺជាថ្មដែលមានកំរិតថ្លាឆ្វះទាប ឬមិនថ្លាឆ្វះ ត្រូវបានគេយកទៅប្រើប្រាស់ជាគ្រឿងលំអផ្សេងៗ មានជាអាទិ៍ កាល់សេដូន អាស្វរីត អូប៉ាល់ធម្មតា អាហ្គាត ហ្សេតម៉ាឡាស៊ីក ឈើថ្ម ថ្មថ្លើមអណ្តើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

**៤-អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ** អាចផ្តល់ឱ្យចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងគោលបំណងកែច្នៃត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ឬថ្មសំអាង ។

**៥-អាជ្ញាប័ណ្ណស្វែងរុករក** អាចផ្តល់ឱ្យចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការស្វែងរុករកនិងសិក្សាអំពីសក្តានុពលធនធានរ៉ែ ។

**៦-អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ** ត្រូវបានផ្តល់ឱ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករកនិងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក ។៚.

សម្បទានិកស្វែងរុករកត្រូវតែដាក់ឱ្យពិនិត្យនូវការវិភាគបច្ចេកទេសហិរញ្ញវត្ថុ បរិស្ថាន សេដ្ឋកិច្ច និងសង្គម ក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ចសង្គមនៃទម្រង់ប្រតិបត្តិការជីកយករ៉ែ ដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

បែបបទនិងមាតិកានៃរបាយការណ៍ ការសិក្សាសមិទ្ធិលទ្ធភាពចុងក្រោយនិងឯកសារយោងព្រមទាំងល័ក្ខខ័ណ្ឌទាំងឡាយនៃការចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនឹងមានចែងក្នុងអនុក្រឹត្យ ។

**មាត្រា ១២.-**

ក្នុងករណីដែលរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែកំណត់ថា ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករក ឬអាជីវកម្មធនធានរ៉ែជាគម្រោងមានទ្រង់ទ្រាយធំនិងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើការចរចាជាមួយអ្នកស្នើសុំដើម្បីឈានទៅដល់កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ដែលត្រូវបន្ថែមទៅលើអាជ្ញាប័ណ្ណធនធានរ៉ែ ។

**មាត្រា ១៣.-**

ចំពោះតំបន់ដែលដឹងពីសក្តានុពលធនធានរ៉ែ ហើយដែលមិនទាន់ចេញអាជ្ញាប័ណ្ណ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចកំណត់តាមការប្រកាសជាសាធារណៈថាជាតំបន់រក្សាទុកសំរាប់ធ្វើការដេញថ្លៃ ដោយរៀបចំឱ្យមានការវាយតម្លៃការចរចាជាផ្លូវការដើម្បីចេញអាជ្ញាប័ណ្ណធនធានរ៉ែសមស្របមួយ ឬតម្រូវឱ្យមានការចរចាធ្វើកិច្ចព្រមព្រៀងធនធានរ៉ែបន្ថែមដូចមានចែងក្នុងមាត្រា ១២ ។

## ជំពូកទី ៤

## នីតិវិធីនៃការចេញអាជ្ញាប័ណ្ណធនធានរ៉ែ

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដោយខ្លួនឯងផ្ទាល់តាមមន្ទីរជំនាញរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែនៅតាមបណ្តាខេត្ត ក្រុង ដែលតំបន់អាជ្ញាប័ណ្ណនោះស្ថិតនៅ ។

មាត្រា ១៥.-

រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែទាំងឡាយផ្សេងទៀតក្រោមអំណាចនៃច្បាប់នេះទៅរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរពីការយល់ព្រម ឬការបដិសេធលើការស្នើសុំអាជ្ញាប័ណ្ណធនធានរ៉ែ ក្នុងរយៈពេលយ៉ាងយូរ ៤៩ (សែសិបប្រាំ) ថ្ងៃ ក្រោយពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស ។

មាត្រា ១៧.-

លើកលែងតែអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ក្រោមអំណោចនៃច្បាប់នេះអាចសុំបន្ត កែប្រែ ប្រគល់ជូនវិញ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬបន្តជាមរតកបានដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ១៨.-

អាជ្ញាប័ណ្ណធនធានរ៉ែក្រោមអំណាចនៃច្បាប់នេះ អាចព្យួរ ឬលុបចោលចំពោះសម្បទានិកណាដែលបំពានច្បាប់នេះ ។

នីតិវិធីនៃការព្យួរទុក ការដកហូតអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៩.-

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ក្រោមអំណាចនៃច្បាប់នេះត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែពិនិត្យនូវលិខិតស្នើសុំរបាយការណ៍ ផែនការនិងលិខិតជូនដំណឹងតាមវេលាកំណត់ហើយត្រូវរក្សាទុកសៀវភៅកំណត់ត្រានិងឯកសារ ។ល។

មាត្រា ២០.-

ការរក្សាការសំងាត់លើឯកសារ ពត៌មានទាំងឡាយដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់នេះ ត្រូវធ្វើរហូតដល់ចុងបញ្ចប់នៃអាជ្ញាប័ណ្ណធនធានរ៉ែ ឬរហូតដល់មានការអនុញ្ញាតពីសម្បទានិកឱ្យធ្វើការផ្សព្វផ្សាយជាចំហលើកលែងតែ :

- ពត៌មានដែលទាក់ទងនឹងបរិស្ថាននិងសង្គមអាចផ្សព្វផ្សាយជាសាធារណៈបានដោយគ្រាន់តែរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែជូនដំណឹងដល់សម្បទានិកនោះប៉ុណ្ណោះ

-ក្រសួងទទួលបន្ទុកវិស័យរ៉ែចងក្រងបោះពុម្ពផ្សាយនូវស្ថិតិដែលស្រង់ចេញពីឯកសារនិងពត៌មានទាំងឡាយរបស់សម្បទានិកឱ្យតែមានការទាក់ទងទៅនឹងការវិភាគផ្នែកធនធានរ៉ែរបស់ជាតិ ។

## ជំពូកទី ៥
## ប្រតិបត្តិការស្វែងរុករកនិងអាជីវកម្មធនធានរ៉ែ

មាត្រា ២១.-

សម្បទានិកឬអ្នកចុះកិច្ចសន្យាបន្តនីមួយៗ ត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការ ស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ នឹងត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោមនេះ :

១-ដំណើការប្រតិបត្តិការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមលក្ខណៈបច្ចេកទេសនិងហិរញ្ញវត្ថុ ដែលនឹងលំអិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិលទ្ធភាពអណ្តូងរ៉ែ

២-ការពារបរិស្ថានដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ

៣-ធានាការការពារសុខភាពនិងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ ។ល។

៤-ការពារសុវត្ថិភាពដល់សាធារណជននៅក្នុងនិងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ

៥-ធ្វើការអប់រំ បណ្តុះបណ្តាលនិងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរដែល នឹងលំអិតក្នុងកម្មវិធីផ្តល់ការងារអប់រំ បណ្តុះបណ្តាល

៦-ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទំនិញនិងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជានៅតាមទីកន្លែង និងពេលវេលាសមស្រប ។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ អាចកំណត់ភាពចាំបាច់បន្ថែមសម្រាប់ការងារខាងលើដោយយោងទៅតាមប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែ និងទំហំប្រតិបត្តិការនោះ ។

មាត្រា ២២.-

ការណែនាំប្រើបែបបទ ការបង្កើន ការពង្រីកផែនការនិងមាតិកានៃរាល់សំណុំលិខិតចាំបាច់និងកម្មវិធីការងារ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់អនុវត្តឱ្យបានត្រឹមត្រូវនោះនឹងមានចែងនៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ២៣.-

ក្នុងករណីចាំបាច់នីមួយៗ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវចាត់តាំងមន្ត្រីមានសមត្ថកិច្ចដើម្បីពិនិត្យការអនុវត្តន៍ច្បាប់នេះ។

មន្ត្រីដែលត្រូវបានចាត់តាំងត្រូវ :

១-ទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែលើរបៀបរបបគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ

២-រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពជាប្រចាំលើការងារស្វែងរុករក និងជីកយករ៉ែតាមឆ្នាំបន្តបន្ទាប់ ហើយដាក់របាយការណ៍នោះជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

៣-ប្រមូលផ្តុំព័ត៌មាននិងរក្សាទុកឯកសារប្រតិបត្តិការស្វែងរុករក ជីកយករ៉ែ ការដឹកជញ្ជូន ប្រព្រឹត្តិកម្ម ការរកទីផ្សារ និងការនាំចេញធនធាននិងផលិតផលរ៉ែ ។ល។

៤-ធ្វើការតាមដាននិងពិនិត្យ ដើម្បីបញ្ជាក់ពីការអនុវត្តន៍បទប្បញ្ញត្តិទាំងអស់នៃច្បាប់នេះ

៥-ត្រួតពិនិត្យការអនុវត្តន៍បទបញ្ជាឱ្យបានត្រឹមត្រូវលើសុខភាព និងសុវត្ថិភាពរបស់ពលករ និងសាធារណជនទូទៅ និងការពារបរិស្ថាន

៦-ទទួលតួនាទីផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

អំណាចនិងតួនាទីរបស់មន្ត្រីដែលត្រូវបានចាត់តាំងដើម្បីត្រួតពិនិត្យធ្វើអធិការកិច្ច និងរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគ ពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រងក្រោមអំណាចនៃច្បាប់នេះនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

**មាត្រា ២៤.-**

តាមការសម្របសម្រួលរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវសុំយោបល់ពីក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តប្រតិបត្តិការស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងមូលដ្ឋាន ខេត្ត ក្រុង ស្រុក ខ័ណ្ឌ តាមគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៦
## សម្បទានិកនិងម្ចាស់កម្មសិទ្ធិដី

**មាត្រា ២៥.-**

សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវសងទៅម្ចាស់កម្មសិទ្ធិដីទាំងក្នុងនិងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែ ចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់ខ្លួនដោយមិនគិតថាការខូចខាតនោះជាឧបទ្ទវហេតុ ឬជាការដឹងមុន ។

ក្នុងករណីការខូចខាតណាដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់សម្បទានិកចាប់ពីពីររូបឡើងទៅ សម្បទានិកទាំងនោះត្រូវរួមគ្នាសងទៅតាមការខូចខាត ។/.

សំណងទាំងនោះត្រូវអនុវត្តដូចខាងក្រោមនេះ :

-ប្រសិនបើជាតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែប៉ះពាល់ទៅលើដីកម្មសិទ្ធិ ម្ចាស់ដីត្រូវអនុញ្ញាតឱ្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែធ្វើប្រតិបត្តិការធនធានរ៉ែនៅលើដីនោះ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកជាមុន ដែលក្នុងនោះម្ចាស់ដីត្រូវបានទទួលសំណងសមរម្យនិងយុត្តិធម៌

-សំណងនោះត្រូវសងតាមពេលវេលា ឬសងផ្តាច់តែម្តងតាមការព្រមព្រៀងរវាងម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ

-ក្នុងករណីម្ចាស់ដីនិងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែមិនអាចស្រុះស្រួលគ្នាលើសំណងបានទេនោះ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសំរួលដោះស្រាយ បើមិនបានសំរេចទេ ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីបង្កើតគណៈកម្មការចំរុះមួយសំរាប់ដោះស្រាយករណីនេះ

-ក្នុងករណីដែលភាគីទាំងអស់មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មការចំរុះទេនោះ សេចក្តីសំរេចជាសមត្ថកិច្ចរបស់តុលាការ ។

## មាត្រា ២៦.-

ក្នុងករណីដែលផ្ទៃដីទាំងមូល ឬបំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ មិនទាន់បានផ្តល់កម្មសិទ្ធិជូនទៅបុគ្គលណាម្នាក់ទេនោះ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញកម្មសិទ្ធិផ្ទៃដីទាំងមូល ឬបំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែទៅឱ្យបុគ្គលណាម្នាក់បានឡើយ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

ប្រសិនបើតំបន់ប្រតិបត្តិការអាជ្ញាប័ណ្ណធនធានរ៉ែនោះមានប្រជាពលរដ្ឋកំពុងរស់នៅមុនកាលបរិច្ឆេទនៃការចេញអាជ្ញាប័ណ្ណ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវអនុវត្តសំណងដូចមានចែងក្នុងមាត្រា ២៥ ដែរ ។៚

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

## ជំពូកទី ៧

## បទប្បញ្ញត្តិហិរញ្ញវត្ថុ

**មាត្រា ២៧.-**

អ្នកដាក់ពាក្យសុំ ឬសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវបង់ជូនរដ្ឋនូវថ្លៃចុះបញ្ជី ពាក្យសុំការពន្យារ បន្ត ការផ្ទេរផ្សេងៗនិងឈ្នួលដីប្រចាំឆ្នាំ ។

**មាត្រា ២៨.-**

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែទាំងអស់ លើកលែងតែសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណស្វែងរុករក និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវសួយសារលើតម្លៃធនធានរ៉ែដែលទាញយកបាន ។

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ ហើយត្រូវផ្តល់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែនូវរបាយការណ៍ ឬបញ្ជីដែលទាក់ទងនឹងពត៌មាននេះ ។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចធ្វើសេចក្តីប្រកាសដល់សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ដើម្បីផ្តល់ពត៌មានបន្ថែមពីកិច្ចសន្យាលក់ អង្កេតនិងតាមដានត្រួតពិនិត្យរាល់បញ្ជីគណនេយ្យ និងពិគ្រោះជាមួយសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដើម្បីកំណត់ថ្លៃផលិតផលរ៉ែ ។

**មាត្រា ៣០.-**

ត្រូវហាមដាច់ខាតក្នុងការដឹកជញ្ជូនធនធានរ៉ែចេញ ក្នុងករណីដែលធនធានរ៉ែនោះមិនទាន់បានបង់សួយសារ ឬគ្មានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។ល។

មាត្រា ៣១.-

យោងតាមច្បាប់ដែលមានជាធរមាន របបពន្ធអាករពិសេសមួយនឹងត្រូវបានបង្កើតឡើងសម្រាប់អនុវត្តលើផលិតផលនិងប្រាក់ចំណូលពីប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែទាំង ៦ (ប្រាំមួយ) ដូចមានចែងក្នុងមាត្រា ១១ ។

មាត្រា ៣២.-

អត្រាសួយសារលើតម្លៃធនធានរ៉ែ នីតិវិធីនៃការបង់សួយសារជូនរដ្ឋនិងការលើកទឹកចិត្តដល់មន្ត្រីមានសមត្ថកិច្ចដែលចែងក្នុងមាត្រា ២៣ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ។

ពន្ធអាករ ពន្ធគយ ពន្ធលើចំណែកភាគហ៊ុន ពន្ធប្រាក់ចំណែកផ្ទាល់ខ្លួន សិរិធានធន បែបបទចំណាយ របៀបបង់ពន្ធ គោលការណ៍ និងការអនុវត្តន៍គណនេយ្យនិងហិរញ្ញកិច្ច ការកំណត់ការខាតបង់ការលើកលែងពន្ធ និងការលើកទឹកចិត្តដល់ការវិនិយោគទុនលើវិស័យរ៉ែ ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

មាត្រា ៣៣.-

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវពិន័យជាប្រាក់ចំនួនពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។ល។

មាត្រា ៣៤.-

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករក ល្មើសនឹងមាត្រា ៧ វាក្យខ័ណ្ឌទី ២ ឬមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

មាត្រា ៣៥.-

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ឬល្មើសនឹងមាត្រា ៧ ឬមាត្រា ៨ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនស្មើនឹង ៣ (បី) ដងនៃតម្លៃថាន់ស្មាន តាមរយៈពេលដែលផលរ៉ែត្រូវបានជីកយកដោយផ្អែកលើទំហំឧបករណ៍ គ្រឿងចក្រផលិតកម្មប្រើប្រាស់និងបរិមាណរ៉ែដែលមានក្នុងទីតាំងនោះ បើពុំកើត ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀលក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលនោះប្រព្រឹត្តខុសរហូតដល់ថ្ងៃដែលសកម្មភាពប្រតិបត្តិការជីកយករ៉ែនោះត្រូវបានបញ្ឈប់ និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត ។ រីឯឧបករណ៍គ្រឿងចក្រផលិតកម្មផ្សេងៗទៀតត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

មាត្រា ៣៦.-

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាប័ណ្ណធនធានរ៉ែអស់សុពលភាព ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

មាត្រា ៣៧.-

សម្បទានិកណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣០ នៃច្បាប់នេះ ត្រូវពិន័យជាប្រាក់ដែលមានចំនួនទ្វេជាពីរនៃតម្លៃធនធានរ៉ែដែលបានដឹកចេញ ឬត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ ឬត្រូវទទួលទោសទាំងពីរ ។ល។

មាត្រា ៣៨.-

សម្បទានិកដែលមិនអនុញ្ញាតឱ្យមន្ត្រីដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ចូលធ្វើការត្រួតពិនិត្យនៅក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែរបស់ខ្លួននឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬត្រូវព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ រយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ ។

ក្នុងករណីមិនរាងចាល ត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែជាស្ថាពរ ។

មាត្រា ៣៩.-

បុគ្គលណាដែលមិនមែនជាម្ចាស់កម្មសិទ្ធិដីស្របច្បាប់ ហើយធ្វើឱ្យរាំងស្ទះដល់ប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែត្រឹមត្រូវតាមច្បាប់នោះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ដល់ ១(មួយ)ខែ ។

មាត្រា ៤០.-

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងទទួលបន្ទុកវិស័យរ៉ែដែលបានឃុបឃិត ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវទទួលទោសវិន័យបាល ដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

មាត្រា ៤១.-

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលបានចាប់ផ្តើមស្វែងរុករកឬធ្វើអាជីវកម្មធនធានរ៉ែ ហើយមានលិខិតអនុញ្ញាតជាផ្លូវការមុនពេលច្បាប់នេះចូលជាធរមាន អាចបន្តសកម្មភាពការងារបាន ប៉ុន្តែតម្រូវឱ្យដាក់ពាក្យបំពេញបែបបទសុំអាជ្ញាប័ណ្ណធនធានរ៉ែថ្មី ទៅតាមបញ្ញត្តិនៃច្បាប់នេះយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ។ល។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

មាត្រា ៤២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។/.

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំគាល់ថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ហត្ថលេខា**

**ស៊ុយ សែម**

លេខ: ១៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២២៥

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ចៅ សែនកុសល ឈុំ អធិបតីនៃសម័យប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ដើម្បីជ្រើសរើសប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិថ្មី ២០០១-២០០៤ ។

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **ប៊ិន ឈិន** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញសំរាប់រយៈពេល ៣ ឆ្នាំ ។

**មាត្រា ២ :** ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សណ្ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២២៧

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

**លោក ខួច ឈៀងស៊ាង**

**ជា**

**ឧត្តញ៉ា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

លេខ: ១៧៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៧០១/២២៨

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **សុខ សាធ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលកិច្ចការរដ្ឋបាលនៃ អាជ្ញាធរប្រេងកាតជាតិកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

លេខ: ១៤៣ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២២៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**លោក តែ តាំងប៉ះ**

**ជា**

**ឧកញ៉ា**

ភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ១៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] ស៊ាន

# ព្រះរាជក្រឹត្យ

## ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋាន
## នៃសមាជិក-សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

នស/រកត/០៧០១/២៣១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រឹទ្ធសភា នីតិកាលទី ១
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃ ទី ១១ ខែ មិនា ឆ្នាំ ១៩៩៩, ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៩ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៩ ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលទី ១
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់ប្រធានព្រឹទ្ធសភា ។

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានបង្កើតសញ្ញាសក្តិ និងឯកសណ្ឋានសំរាប់សំគាល់សមាជិក-សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ .-**

សញ្ញាសក្តិ រួមមាន សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាង ។

ឯកសណ្ឋាន រួមមាន ឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ ។

**មាត្រា៣ .-**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភាត្រូវបានកំណត់ដូចខាងក្រោម :

- ឯកសណ្ឋានផ្លូវការ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ ពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ និងរបស់ព្រឹទ្ធសភា ជាពិសេស ក្នុងពិធីបើកជាផ្លូវការនៃសម័យប្រជុំនីមួយៗរបស់ព្រឹទ្ធសភា បន្ទាប់ពីវិស្សមកាល ។
- ឯកសណ្ឋានប្រពៃណីជាតិ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ជាពិសេស ក្នុងឱកាសពិធីបើកជាផ្លូវការនៃនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា ។

សមាជិក-សមាជិកាព្រឹទ្ធសភា ប្រើប្រាស់ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬរបស់ក្រសួងព្រះបរមរាជវាំង ឬរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឬរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា៤ .- អំពីសញ្ញាសក្តិ**

សញ្ញាសក្តិនៃសមាជិក-សមាជិកាព្រឹទ្ធសភាត្រូវបានកំណត់ដូចតទៅ :

**១- សំរាប់ប្រធាន អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការនៃព្រឹទ្ធសភា**

**ក-__សក្តិស្មា:__** មានផ្ទៃកម្ពីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់អង្ករពណ៌មាសចំកណ្តាល ។ នៅពីខាងលើក្បាច់អង្ករ មានសញ្ញាព្រឹទ្ធសភាពណ៌មាស ហើយនៅពីខាងលើសញ្ញាព្រឹទ្ធសភា មានឡេវមួយគ្រាប់រូបព្រះសង្ខាពណ៌មាស ។ មានពួរវេញមួយខ្សែពណ៌មាស ព័ទ្ធជុំវិញរូបភាពទាំង៣នេះ ។ នៅផ្នែកខាងក្រៅពួរវេញនេះ មានរាយជាក្បាច់ចក(មូល១) ជាល់អជរជាយ ។ ដោយឡែក នៅបាតក្រោមនៃសក្តិមានក្បាច់ចក(មូល១)ធំបី ជានិមិត្តសញ្ញាតំណាងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ។ នៅតាមគែមនៃសក្តិខាងក្រៅ៤.ក.

មានក្បាច់ជរជាយជាពួរវេញពណ៌មាស បីផ្កាតសំរាប់សំគាល់ឋានន្តរស័ក្តិប្រធានព្រឹទ្ធសភា ពីរផ្កាតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយផ្កាត សំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

- បាតក្រោមប្រវែង ៥.៥០ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៥៧ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

**ខ_សក្តិចុងកអាវ** : មានផ្ទៃកម្ទីពណ៌ខៀវ រចនាតុបតែងដោយក្បាច់អង្គរពណ៌មាស និងមានសញ្ញាព្រឹទ្ធសភានៅខាងដើម ។ មានផ្កាតពួរវេញពណ៌មាសមួយផ្កាតព័ទ្ធជុំវិញក្បាច់អង្គរ និងសញ្ញាព្រឹទ្ធសភា ។ នៅផ្នែកខាងមុខ ក្រៅរង្វង់ផ្កាតពួរវេញនេះ មានកួរស្រូវពណ៌មាសមួយកួរ មាន៩គ្រាប់ជានិមិត្តសញ្ញានៃសេដ្ឋកិច្ចកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ជាង៩០%ជាកសិករ ។ នៅផ្នែកខាងលើនៃសក្តិ មានក្បាច់ចក(មូល៧)រាយជាជួរលំអជរជាយ ។ ដោយឡែក នៅគែមខាងមុខ និងខាងលើនៃសក្តិចុងកអាវនេះ មានផ្កាតពណ៌មាសបីជាសញ្ញាសំគាល់ឋានន្តរសក្តិប្រធានព្រឹទ្ធសភា ពីរផ្កាតសំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយផ្កាតសំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ
- ទទឹងប្រវែង ៣.៥០ សង្ទីម៉ែត្រ

**គ_សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ទីពណ៌ខៀវ រចនាតុបតែងដោយក្បាច់អង្គរពណ៌មាស មានក្បាច់ចកពណ៌មាសរាយលំអជរជាយពីខាងលើ និងចំហៀងទាំងសងខាង ។ ជាពិសេស មានផ្កាតពណ៌មាសបីតាមគែមសក្តិខាងលើ និងចំហៀងសងខាងសំរាប់សំគាល់ឋានន្តរសក្តិប្រធានព្រឹទ្ធសភា ពីរផ្កាតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយផ្កាតសំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។ ដោយឡែក នៅជុំវិញក្បាច់អង្គរ មានពួរវេញមួយខ្សែព័ទ្ធជុំវិញផងដែរ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រចំពោះនារី អាស្រ័យលើមាឌ ម.ក.

- ទទឹងប្រវែង ៩ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មាបក្តិចុងកអាវ និងផក្តិចុងដៃអាវ សំរាប់ប្រធានព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១ សំរាប់អនុប្រធានព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ និងសំរាប់ប្រធានគណៈកម្មការនៃព្រឹទ្ធសភា មានគំរូ ដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ ។

## ២. សំរាប់អនុប្រធានគណៈកម្មការ និងសមាជិក-សមាជិកាព្រឹទ្ធសភាដទៃទៀត

**ក-<u>សក្តិស្មា</u>:** មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាសចំកណ្តាល ។ នៅពីខាងលើក្បាច់ភ្ញីទេស មានសញ្ញាព្រឹទ្ធសភាពណ៌មាស ហើយនៅពីខាងលើសញ្ញាព្រឹទ្ធសភា មានឡេវមួយគ្រាប់រូបព្រះសង្ខាពណ៌មាស ។ មានក្បូរវេញមួយខ្សែពណ៌មាស ព័ទ្ធជុំវិញរូបភាពទាំង៣នេះ ។ នៅផ្នែកខាងក្រៅពួរវេញនេះ មានរាយជាក្បាច់ចក(មូល១) ជាលំអជរជាយ ។ ដោយឡែក នៅបាតក្រោមនៃសក្តិមានក្បាច់ចក (មូល១) ធំបី ជានិមិត្តសញ្ញាតំណាងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ។ នៅតាមគែមនៃសក្តិខាងក្រៅមានក្បាច់ជរជាយជាពួរវេញពណ៌មាស ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានគណៈកម្មការ និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

- បាតក្រោមប្រវែង ៥.៥០ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៥០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

**ខ-<u>សក្តិចុងកអាវ</u> :** មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានសញ្ញាព្រឹទ្ធសភានៅខាងដើម ។ មានឆ្នូតពួរវេញពណ៌មាសមួយឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីទេស និងសញ្ញាព្រឹទ្ធសភា ។ នៅផ្នែកខាងមុខ ក្រៅរង្វង់ឆ្នូតពួរវេញនេះ មានកួរស្រូវពណ៌មាសមួយកួរ មាន៩គ្រាប់ជានិមិត្តសញ្ញានៃសេដ្ឋកិច្ចកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ជាង៩០%ជាកសិករ ។ នៅផ្នែកខាងលើនៃសក្តិមានក្បាច់ចក(មូល១)រាយជាជួរលំអជរជាយ ។ ដោយឡែក នៅគែមខាងមុខ និងខាងលើនៃសក្តិចុងកអាវនេះ មានឆ្នូតពណ៌មាសពីរជាសញ្ញាសំគាល់ឋានន្តរសក្តិអនុប្រធានគណៈកម្មការ និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ ។ល។

- ទទឹងប្រវែង ៣.៥០ សង្ទីម៉ែត្រ

**គ_សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស មានក្បាច់ចកពណ៌មាសរាយលំអជរដោយពីខាងលើ និងចំហៀងទាំងសងខាង ។ ជាពិសេស មានផ្កូតពណ៌មាសពីរតាមគែមសក្តិ ខាងលើ និងចំហៀងទាំងពីរសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានគណៈកម្មការ និងមួយផ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។ ដោយឡែក នៅជុំវិញក្បាច់ភ្ញីទេសមានពួរវេញមួយខ្សែព័ទ្ធជុំវិញផងដែរ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ២៨ សង្ទីម៉ែត្រចំពោះនារីអាស្រ័យលើមាឌ
- ទទឹងប្រវែង ៩ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់អនុប្រធានគណៈកម្មការព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។ រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែក សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាងរបស់នារី មានទំហំតូចដូចខាងក្រោមនេះ :

- សក្តិស្មាអាចមានទំហំ ៨០%, ៨៥%, ៩០% នៃទំហំសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងកអាវ មានទំហំ ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី

**មាត្រា៥ .- អំពីឯកសណ្ឋាន**

ឯកសណ្ឋានសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា ត្រូវបានកំណត់ដូចខាងក្រោម :

**១_ ឯកសណ្ឋានផ្លូវការ**

**ក_ចំពោះបុរស** : ។ល។

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវ មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិ ខាងលើពីរខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ អាវបិទឡេវមុខ ដោយដាក់ឡេវរូបព្រះសង្ខាចំនួនប្រាំពីរ ។

- ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**ខ_ចំពោះនារី :**

- អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបសញ្ញាព្រះសង្ខាចំនួនប្រាំពីរ ។ ចុងកអាវទាំងសងខាង មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរខាងក្រោមពីរ ដៃវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

ឯកសណ្ឋានផ្លូវការមាន ៣ប្រភេទ :

- ប្រើសំពត់សំឡូយអំពីផាទុងពណ៌ព្រីងទុំ ចាក់ជើងអំពីសូត្រ ពណ៌ខ្ចីជាងពណ៌សំពត់ ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ១ ។

- ប្រើសំពត់សំឡូយអំពីផាមួងពណ៌ព្រីងទុំ ចាក់ជើងសែសយពណ៌ប្លាទីនមាស តាមក្បាច់ជរជើងឯកភាពគ្នា ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ២ ។

- ប្រើសំពត់សំឡូយអំពីហូល តាមគោមឯកភាពគ្នា ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ៣ ។

- ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ស កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹកដល់ថ្ងៃត្រង់ ។

- ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ខ្មៅ កាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យនេះ ។

**២_ ឯកសណ្ឋានប្រពៃណីជាតិ**

**ក_ចំពោះបុរស :** ង.។.

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវ មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ អាវបិទមុខដោយដាក់ឡេវរូបសញ្ញាព្រះសង្ខចំនួនប្រាំពីរ ។

- សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ជង្គង់ ។

**ខ_ចំពោះនារី :**

- អាវជីបរាងអំពីក្រណាត់ប៉ាក់ពណ៌ស ដៃវែងត្រឹម៣/៤ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិត ១.៥០ សង្ទីម៉ែត្រ និងត្រង់ស្មា ឃ្លាតពីគល់កប្រមាណ ២.៥០ សង្ទីម៉ែត្រ ទៅ ៣.00 សង្ទីម៉ែត្រអាស្រ័យទៅតាមមាឌរបស់នារី ។

- ពានាក្រមាអំពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬក្រមាសូត្រពណ៌ស៊ីនូន តាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬរបស់ក្រសួងព្រះបរមរាជវាំង ឬរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឬ របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ដោយប្រើកន្ទាស់សំរាប់ខ្ទាស់ក្រមាពានាជាកន្ទាស់អំពីសញ្ញាព្រឹទ្ធសភា ដែលមានទំហំទទឹង ៥ សង្ទីម៉ែត្រ និង កំពស់ ៧ សង្ទីម៉ែត្រ ។

ឯកសណ្ឋានប្រពៃណីជាតិ មាន ២ ប្រភេទ :

- ឯកសណ្ឋានប្រពៃណីជាតិ ដែលប្រើសំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ និងពានាក្រមាពណ៌ខ្ចីជាងសំពត់ ហៅថាឯកសណ្ឋានប្រពៃណីជាតិ ប្រភេទលេខ ១ ។

- ឯកសណ្ឋានប្រពៃណីជាតិ ដែលប្រើសំពត់ហូលតាមគោមឯកភាពគ្នា និងពានាក្រមាពណ៌ស៊ីនូន ហៅថាឯកសណ្ឋានប្រពៃណីជាតិ ប្រភេទលេខ ២ ។

- ស្បែកជើងពណ៌ស និង កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ថ្ងៃត្រង់ ។

- ស្បែកជើងពណ៌ខ្មៅ និងកាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យនេះ ។ រូបគំនូរកន្ទាស់ព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។/.

**មាត្រា ៦ .-**

ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ ២០០១

លេខៈ ១៨០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ ចាន់**

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ..នស/រកត/០៧០១/២៣..
ចុះថ្ងៃទី ១២..ខែកក្កដាឆ្នាំ..២០០១...ស្ដីពីសញ្ញាសក្ដិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

# ប្រធានព្រឹទ្ធសភា

សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ.នស/រកត/០៧០១/២៣១

ចុះថ្ងៃទី ១២..ខែ.កក្កដា.ឆ្នាំ.២០០១...ស្ដីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ

សមាជិក-សមាជិកាព្រឹទ្ធសភា

## អនុប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ណ.ភ.

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ......................
ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០១.....ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

## ប្រធានគណៈកម្មការព្រឹទ្ធសភា



សក្តិស្មា



សក្តិចុងករអាវ



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យលេខ......................................
ចុះថ្ងៃទី១២..ខែ......ឆ្នាំ..............ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

## អនុប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/[illegible]
ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

សមាជិក-សមាជិកាព្រឹទ្ធសភា

សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ



## ឯកសណ្ឋានផ្លូវការ



ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃសមាជិក-សមាជិកាព្រឹទ្ធសភា ។

## ឯកសណ្ឋានប្រពៃណីជាតិ



ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃសមាជិក-សមាជិកាព្រឹទ្ធសភា ។

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១
ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីកន្លាស់សញ្ញាព្រឹទ្ធសភានៃ
សមាជិក-សមាជិកាព្រឹទ្ធសភា ព.ទ.

# កន្លាស់សញ្ញាព្រឹទ្ធសភា



# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៣២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម ឆ្នាស់ ផល្លី អត្តលេខ ០០៣២៣៧ ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក និងមានឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១

លេខ: ៤៤២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៦២...អនក្រ. បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៦.៨០០ លានរៀល ( ប្រាំមួយពាន់ប្រាំបីរយលានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់សងបំណុលប្រេងឥន្ទនៈឆ្នាំ ២០០០,សោហ៊ុយទទួលភ្ញៀវបរទេស និង ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១៥០ លានរៀល ( មួយរយហាសិបលានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ផ្តល់មូលនិធិដំបូងជូនអាជ្ញាធរអគ្គិសនីកម្ពុជា។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០៧អនក្រ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

2

# សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ និងគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ និងត្រួតពិនិត្យរាល់សកម្មភាព ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា របស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដើម្បីធានាឱ្យមានសន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់សង្គម នៅតំបន់ព្រំដែន និងក្នុងផ្ទៃប្រទេស កិច្ចការពារសុខុមាលភាព ជូនប្រជាពលរដ្ឋ និងចំណូលថវិកាជាតិ ។

## ជំពូកទី ២
## និយមន័យ

**មាត្រា ២ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈអន្តរជាតិ និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅតាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែអន្តរជាតិក្នុងផ្ទៃប្រទេស ដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈអន្តរជាតិទ្វេភាគីតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ដែលស្ថិតនៅលើខ្សែបន្ទាត់ព្រំដែន ដូចមានចែងក្នុងមាត្រា ៨ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈទ្វេភាគីលក្ខណៈតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារព្រំដែនទ្វេភាគី ដែលស្ថិតលើខ្សែបន្ទាត់ព្រំដែន ដូចមានចែងក្នុង

3

មាត្រា ៩ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ស្របតាមកិច្ចព្រមព្រៀងទ្វេភាគី រវាងប្រទេសជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ជាទីតាំងរបស់អង្គភាពចំរុះ ធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ ដែលជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែននោះ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារព្រំដែន ដែលស្ថិតនៅលើខ្សែបន្ទាត់ព្រំដែន ស្របតាមកិច្ចព្រមព្រៀងរវាងប្រទេសជាប់ព្រំដែន ជាមួយព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា ១០ ជំពូក ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ គឺជាទីតាំងរបស់អង្គភាពចំរុះ ធ្វើការត្រួតពិនិត្យការចេញ-ចូលកំពង់ផែសមុទ្រ និងការធ្វើសកម្មភាពរបស់អ្នកដំណើរជាប្រជាពលរដ្ឋ នៃប្រទេសជាប់ព្រំដែន មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារកំពង់ផែសមុទ្រ ដែលស្ថិតនៅក្នុងប្រទេស ដូចមានចែងក្នុងមាត្រា ១១ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣

## ការកំណត់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ

**មាត្រា ៧ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ :

- រាជធានីភ្នំពេញ : អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និងកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ
- ក្រុងព្រះសីហនុ : កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ
- ខេត្តសៀមរាប : អាកាសយានដ្ឋានសៀមរាប ។

**មាត្រា ៨ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារព្រំដែនអន្តរជាតិ :

- ខេត្តស្វាយរៀង : បាវិត
- ខេត្តកណ្តាល-ព្រៃវែង : ក្អមសំណរ-កោះរការ
- ខេត្តតាកែវ : ភ្នំដិន

- ខេត្តកោះកុង : ចាំយាម
- ខេត្តបន្ទាយមានជ័យ : ប៉ោយប៉ែត
- ខេត្តស្ទឹងត្រែង : ដុងក្រឡ ។

**មាត្រា ៩ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី :

- ខេត្តរតនគិរី : អូរយ៉ាដាវ
- ខេត្តមណ្ឌលគិរី : ដាក់ដាំ
- ខេត្តព្រះវិហារ : ប្រាសាទព្រះវិហារ
- ខេត្តក្រចេះ : ស្នួល
- ខេត្តកំពង់ចាម : ត្រពាំងផ្លុង
- ខេត្តកំពត : ព្រែកចាក
- ខេត្តស្វាយរៀង : ព្រៃវល្លិ៍ ។

**មាត្រា ១០ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន :

- ខេត្តមណ្ឌលគិរី : ឡាប៉ាខេ
- ខេត្តក្រចេះ : ជ័យឃ្លាំង និងត្រពាំងស្រែ
- ខេត្តកំពង់ចាម : ចាន់មូល ដា និង ជាំក្រវៀន
- ខេត្តព្រៃវែង : ពាមមន្ទា និងកោះសំពៅ
- ខេត្តស្វាយរៀង : សំរោង បុសមននិងស្រែបារាំង
- ខេត្តកណ្ដាល : ជ្រៃធំ-ខ្នាតាំងយូ
- ខេត្តតាកែវ : បាក់ដៃ និងកំពង់ក្រសាំង
- ខេត្តកំពត : តន់ហាន់
- ខេត្តពោធិ៍សាត់ : ភ្នំប្ញស្សី ស្ពានជ័យជំនះ និងច្រកផ្លូវ ៥៦
- ខេត្តបន្ទាយមានជ័យ: បឹងត្រកួន និងមេឡៃ
- ខេត្តឧត្តរមានជ័យ : អូរស្មាច់ ជាំប្ញសង់ និងព្រះប្រឡាយ
- ខេត្តព្រះវិហារ : អានសេះ
- ខេត្តបាត់ដំបង : ភ្នំដី សូនស៊ុំ ច្រក ៤០០ ច្រក ២០៣ ពាមតា ម៉ានជៀនឆាវ ភ្នំព្រឹក ស្វាយចេក និងអូររំដួល

- ក្រុងប៉ៃលិន : ច្រកព្រំ ។

**មាត្រា ១១ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ :

- ខេត្តកំពត : កោះសេះ ត្រពាំងល្ពៅ និងទីរួមខេត្ត
- ទីក្រុងកែប : ទីក្រុងកែប
- ក្រុងព្រះសីហនុ : ទំនប់រលក និងស្ទឹងហាវ
- ខេត្តកោះកុង : បាក់ខ្លង ថ្មស រែស្រែអំបិល និងកោះស្តេច ។

## ជំពូកទី ៤

## ការកំណត់ភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ

**មាត្រា ១២ .-**

- ភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យច្រកទ្វារគ្រប់ប្រភេទ គឺជាដែនធ្វើសកម្មភាពត្រួតពិនិត្យដោយមន្ត្រីភ្នាក់ងារមានសមត្ថកិច្ចនៃទីស្នាក់ការត្រួតពិនិត្យនីមួយៗ ។
- ទំហំទីតាំងនៃទីស្នាក់ការត្រួតពិនិត្យច្រកទ្វារនីមួយៗ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- ចំពោះទីស្នាក់ការត្រួតពិនិត្យអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និងអាកាសយានដ្ឋានសៀមរាប ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។
- ចំពោះទីស្នាក់ការត្រួតពិនិត្យកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ក្នុងករណីមានវត្តមាន អនុវរៈការពារព្រំដែននៃក្រសួងការពារជាតិ ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងការពារជាតិដែរ ។
- ទំហំទីតាំងជាក់ស្តែងនៃភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែន ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបន្ទាប់ពីមានការ ឯកភាពពីគណៈកម្មាធិការចំរុះកិច្ចការព្រំដែន ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______



## ជំពូកទី ៥

## សមាសភាព

**មាត្រា ១៣ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ :

ក/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង :

១- មន្ត្រីអាជ្ញាធរអាកាសចរស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាប្រធាន និងជំនួយការ ចំនួន ០២នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ជាអនុប្រធាន និងសហការី ចំនួន ៤៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក និងសហការី ចំនួន ៦៣នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១៥នាក់ ។

ខ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ :

១- មន្ត្រីកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជាប្រធាន និងជំនួយការ ចំនួន ០៣នាក់

២- មន្ត្រីនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ជាអនុប្រធាន និងសហការី ចំនួន ២៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក និងសហការី ចំនួន ៣០នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១៤នាក់

៥- មន្ត្រីកាំសាប ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក និងសហការី ចំនួន ០២នាក់ ។

គ/- ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែអន្តរជាតិ ក្រុងព្រះសីហនុ :

១- មន្ត្រីកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជាប្រធាន និងជំនួយការ ចំនួន ០៣នាក់

២- មន្ត្រីនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន និងសហការី ចំនួន ៤៩នាក់

7

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ៤៧នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ២៩នាក់

៥- មន្ត្រីកាំសាបក្រសួងសាធារណការ និងដឹកជញ្ជូន

ជាសមាជិក និងសហការី ចំនួន ០២នាក់ ។

ឃ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានសៀមរាប :

១- មន្ត្រីអាជ្ញាធរអាកាសចរស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ជាប្រធាន និងជំនួយការ ចំនួន ០២នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១០នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៣នាក់ ។

**មាត្រា ១៤ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ :

ក/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត :

១- អភិបាលខេត្តបន្ទាយមានជ័យ ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ៣៦នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១១នាក់ ។

ខ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិបាវិត :

១- អភិបាលខេត្តស្វាយរៀង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៤

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ២៤នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៩នាក់ ។

គ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន :

១- អភិបាលខេត្តតាកែវ ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១៥នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៨នាក់ ។

ឃ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម :

១- អភិបាលខេត្តកោះកុង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១២នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៦នាក់ ។

ង/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ-កោះរកា :

១- អភិបាលខេត្តកណ្តាល ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ២៤នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៩នាក់ ។

ច/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិដូងក្រឡូ :

១- អភិបាលខេត្តស្ទឹងត្រែង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

9

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៨នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១៥នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៦នាក់ ។

**មាត្រា ១៥ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគបាលជាតិ ការិយាល័យជនបរទេស នៃស្នងការនគរបាល ខេត្ត-ក្រុង សាមី

ជាអនុប្រធាន និងសហការី ចំនួន ២៨នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួនពី ០៣ ទៅ ២៩នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៧នាក់ ។

ដោយឡែកនៅច្រកទ្វារប្រាសាទព្រះវិហារ :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលាខេត្តព្រះវិហារ

ជាប្រធាន និងសហការី ចំនួន ០៣នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៨នាក់

៣- មន្ត្រីក្រសួងទេសចរណ៍ ជាសមាជិក និងសហការី ចំនួន ១២នាក់ ។

**មាត្រា ១៦ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគរបាលជាតិ នាយកដ្ឋាននគរបាលការពារព្រំដែនគោក

ជាអនុប្រធាន និងសហការី ចំនួន ២៨នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួនពី ០៤ ទៅ ៣៧នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៥នាក់ ។

មាត្រា ១៧ .-

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគរបាលជាតិ ការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាល ខេត្ត-ក្រុង

ជាអនុប្រធាន និងសហការី ចំនួន ២៤នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១២នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៥នាក់ ។

ដោយឡែកនៅទីស្នាក់ការត្រួតពិនិត្យកំពង់ផែសមុទ្រ កោះសេះ នាយនគរបាលជាតិ នាយកដ្ឋាន-នគរបាលព្រំដែនទឹក ជាអនុប្រធាន និងសហការី ចំនួន ១២នាក់ ។

## ជំពូកទី ៦

## ភារកិច្ច

មាត្រា ១៨ .-

ប្រធានទីស្នាក់ការត្រួតពិនិត្យ មានភារកិច្ច :

- ធ្វើជាអធិបតី ក្នុងសម័យប្រជុំនានារបស់ទីស្នាក់ការត្រួតពិនិត្យ
- ដឹកនាំកិច្ចការ រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ពេលប្រជុំ
- ធានាឱ្យមានកិច្ចប្រជុំរួមនៃគ្រប់តំណាងមានសមត្ថកិច្ច នៃទីស្នាក់ការត្រួតពិនិត្យ យ៉ាងហោចណាស់ឱ្យបានមួយដងក្នុងមួយខែ
- ធានាដឹកនាំផ្ទាល់ គ្រប់អង្គភាពចំណុះទីស្នាក់ការត្រួតពិនិត្យ ឱ្យដំណើរការបានត្រឹមត្រូវ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធនានា និងបទបញ្ជាផ្ទៃក្នុងនៃទីស្នាក់ការត្រួតពិនិត្យ
- ដឹកនាំកិច្ចការថែរក្សាការពារអធិបតេយ្យភាព បូរណភាពទឹកដី
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

11

- សំរបសំរួលការងារក្នុងទីស្នាក់ការត្រួតពិនិត្យឱ្យមានភាពរលូន
- ដឹកនាំការងាររបស់ទីស្នាក់ការត្រួតពិនិត្យ និងរាយការណ៍ រាល់សកម្មភាពការងាររបស់កងកំលាំងនគរបាលជាតិ មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ទៅក្រសួង ស្ថាប័នសាមី ក្នុងករណីបុគ្គលណា ឬអង្គភាពណាប្រព្រឹត្តបទល្មើស
- ដឹកនាំកិច្ចការ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេស និងសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសជាប់ព្រំដែន ដើម្បីធានារក្សាការអនុវត្តន៍ត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់របស់ប្រទេសនីមួយៗ
- ដឹកនាំ និងគ្រប់គ្រងការសាងសង់ជួសជុល និងរក្សាទីតាំងការត្រួតពិនិត្យរួមមួយឱ្យបានរឹងមាំល្អ សមស្របតាមសំណង់វប្បធម៌ជាតិ ធានាបានការលើកតំកើងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា និងប្រសិទ្ធភាពការងារដោយសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីចៀសវាងឱ្យបាននូវការលំបាករបស់អ្នកឆ្លងកាត់
- ធានាឱ្យមានកន្លែងត្រួតពិនិត្យតែមួយរួមគ្នា
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័ន សាមី តាមរយៈអភិបាល ខេត្ត-ក្រុង សាមី ។

**មាត្រា ១៩ .-**

មន្ត្រីនគរបាលជាតិ នៅច្រកទ្វារ មានភារកិច្ចៈ

- ត្រួតពិនិត្យអ្នកដំណើរ ចេញ-ចូលប្រទេស និងចេញ-ចូលតំបន់ព្រំដែនទាំងសញ្ជាតិបរទេស និងសញ្ជាតិខ្មែរ
- សហការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដែល ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា សំដៅរកឃើញ និងបង្ក្រាបទាន់ពេលវេលា បទល្មើសឆ្លងដែន ការរត់ពន្ធ ជួញដូរមនុស្សខុសច្បាប់ ជួញដូរស្ត្រី និងកុមារ ការធ្វើចរាចររូបិយវត្ថុក្លែងក្លាយ ការជួញដូរគ្រឿងញៀន វត្ថុបុរាណ ការដឹកជញ្ជូន និងការជួញដូរ ការប្រើប្រាស់អាវុធជាតិផ្ទុះ និងបរិក្ខារសិកខុសច្បាប់ និងបទល្មើសផ្សេងៗទៀត ដើម្បីរក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សង្គម
- ត្រួតពិនិត្យ និងថែរក្សាស្ថានភាពដដែល នៃខ្សែបន្ទាត់ព្រំដែន ដែលស្ថិតក្នុងភូមិសាស្ត្រច្រកទ្វារនីមួយៗ
- ចាត់វិធានការរក្សា សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងភូមិសាស្ត្រច្រកទ្វារ ហើយក្នុងករណីចាំបាច់ត្រូវសហការ និងសុំអន្តរាគមន៍ពីអាជ្ញាធរដែនដីដែលពាក់ព័ន្ធ

- ដោយឡែកកំលាំងនគរបាលជាតិ នាយកដ្ឋានជនបរទេស ដែលបំពេញភារកិច្ចនៅច្រកទ្វារកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ ត្រូវចាត់វិធានការអមការពារនាវា ពីចំណុចកណ្ដាលមកកំពង់ផែ ។

មាត្រា ២០ .-

ភ្នាក់ងារគយ និរដ្ឋាករ មានភារកិច្ច :

- គ្រប់គ្រងត្រួតពិនិត្យ និងប្រមូលពន្ធ អាករ ព្រមទាំងកំរៃនានា លើទំនិញ និងមធ្យោបាយដឹកជញ្ជូននាំចេញ នាំចូលគ្រប់ប្រភេទ រួមទាំងឥវ៉ាន់អ្នកដំណើរ កញ្ចប់ប្រៃសណីយ៍ រូបិយវត្ថុ លោហធាតុ ឬត្បូងថ្មមានតំលៃ ព្រមទាំងសារធាតុផ្សេងៗទៀត ដែលមានចែងក្នុងតារាងពន្ធគយ នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមនីតិវិធីគយ និងបទបញ្ញត្តិច្បាប់ ពាក់ព័ន្ធផ្សេងទៀតជាធរមាន ។
- បញ្ជាក់លទ្ធផលនៃការត្រួតពិនិត្យនៅលើប្រតិវេទន៍គយ ហើយក្នុងករណីរកឃើញបទល្មើសគយ ត្រូវធ្វើកំណត់ហេតុបទល្មើស និងចាត់ចែងឃាត់ ឬរក្សាទុកជាបណ្ដោះអាសន្ននូវទំនិញ ឬមធ្យោបាយល្មើសនេះ រង់ចាំការសំរេចពីស្ថាប័នមានសមត្ថកិច្ច ។
- ក្នុងករណីយល់ថាចាំបាច់ ភ្នាក់ងារគយ និងរដ្ឋាករ ត្រូវស្នើសុំកិច្ចសហការពីអាជ្ញាធរ ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ក្នុងពេលចុះត្រួតពិនិត្យរកបទល្មើសគយនានា ។

មាត្រា ២១ .-

ភ្នាក់ងារកាំកុងត្រូលមានភារកិច្ច :

- ត្រួតពិនិត្យលើបរិមាណទំងន់ គុណភាព សភាពផលិតផលនៃទំនិញ នាំចេញ-នាំចូល និងចេញវិញ្ញាបនប័ត្របញ្ជាក់លើបរិមាណ គុណភាពទំនិញ និងសភាពផលិតផល នៃទំនិញ នាំចេញ-នាំចូល
- លើកវិធានការរាំងខ្ទប់ និងចាប់ឃាត់ទំនិញ នាំចេញ-នាំចូល ខូច ឬអន់គុណភាព និងបង្ក្រាបការក្លែងបន្លំ
- ប្រមូលប្រាក់កំរៃ ដែលបានមកពីការត្រួតពិនិត្យទំនិញនាំចេញ-នាំចូល បង់ចូលថវិការដ្ឋ ។

មាត្រា ២២ .-

ភ្នាក់ងារក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ច :

- ពិនិត្យ និងសំរួលការស្នើសុំចូលចតនៅផែអន្តរជាតិរាជធានីភ្នំពេញ និងកំពង់ព្រះសីហនុ សំរាប់នាវាដឹកទំនិញ និងនាវាទេសចរណ៍គ្រប់ប្រភេទ

- ត្រួតពិនិត្យកត់ត្រា និងធ្វើរបាយការណ៍ជាប្រចាំ អំពីបរិមាណនាវា បរិមាណទំនិញឆ្លងកាត់ ការខូចខាត ឬ បាត់បង់ ទំនិញសំរាប់ការនាំចេញ-នាំចូល ព្រះរាជាណាចក្រកម្ពុជា
- សំរួលការស្នើសុំ កណ្ណាធាការ សំរាប់នាំនាវាចូល ចេញពីកំពង់ផែអន្តរជាតិ ។

មាត្រា ២៣ .-

- ក្រុមគយ និងរដ្ឋាករចល័ត ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់នាយកទីចាត់ការគយ និងរដ្ឋាករ មានភារកិច្ចធ្វើការស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធ ពីច្រកទ្វារព្រំដែន ចូលមកផ្ទៃក្នុងប្រទេស ។
- ក្រុមគយ និងរដ្ឋាករចល័តនេះ អាចចេញធ្វើប្រតិបត្តិការឃាត់មធ្យោបាយដឹកទំនិញបាន ក្នុងពេលណាដែលទទួលពត៌មានថា មធ្យោបាយដឹកទំនិញនោះ កំពុងប្រព្រឹត្តអំពើរត់គេចពន្ធ ពីព្រំដែនចូលមកផ្ទៃក្នុងប្រទេស និងមានបញ្ជាបេសកកម្មពីនាយកទីចាត់ការគយ និងរដ្ឋាករ តាមករណីជាក់ស្តែងនីមួយៗ ។ មិនអនុញ្ញាតឱ្យក្រុមគយ និងរដ្ឋាករចល័តនេះ ធ្វើសកម្មភាពបែបអនាធិបតេយ្យឡើយ ។

មាត្រា ២៤ .-

មន្ត្រីភ្នាក់ងារ មានសមត្ថកិច្ចគ្រប់ជំនាញ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនក្រសួង ស្ថាប័នសាមី និងប្រធានទីស្នាក់ការ ។

មាត្រា ២៥ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ចទាំងអស់នៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវសហការធ្វើការត្រួតពិនិត្យស្របពេលជាមួយគ្នា តាមជំនាញ និងដោយឆាប់រហ័សតាមទំហំការងារ នៅកន្លែងតែមួយ ដោយហាមឃាត់មិនឱ្យមានការបើកផែកទំនិញលើសពីមួយដង សំរាប់រយៈពេលឆ្លងកាត់ច្រកទ្វារទាំងមូល ។ ក្នុងករណីកំលាំងឬភ្នាក់ងារណា ពុំបានចូលរួមត្រួតពិនិត្យតាមការកំណត់របស់ប្រធានទីស្នាក់ត្រួតពិនិត្យទេនោះ គឺត្រូវចាត់ទុក ថាបានត្រួតពិនិត្យរួចហើយ ។

ការត្រួតពិនិត្យបែបបទ របស់មន្ត្រីមានសមត្ថកិច្ច លើនាវាអន្តរជាតិដែល ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា តាមច្រកសមុទ្រ ឬច្រកទន្លេមេគង្គ ត្រូវធ្វើតែម្តងគត់ពេលនាវាចូលដល់កំពង់ផែគោលដៅក្រុងព្រះសីហនុ ឬកំពង់ផែគោលដៅរាជធានីភ្នំពេញ ។ នៅច្រកទន្លេមេគង្គ ភ្នាក់ងារគយ និងរដ្ឋាករ និងមន្ត្រីនគរបាលច្រកទ្វារព្រំដែន អាចចាត់តាំងភ្នាក់ងារ និងមន្ត្រីអមនាវា ក្នុងករណីចាំបាច់ ។

ការឈប់សំចតរបស់នាវាអន្តរជាតិ នៅតាមទីតាំងចំណតផែដទៃទៀត ក្រៅតំបន់ភូមិសាស្ត្រកំពង់ផែដែលបានកំណត់ ត្រូវមានការអនុញ្ញាតជាមុន ពីប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិកំពង់ផែ ក្រុងព្រះសីហនុ ឬកំពង់ផែរាជធានីភ្នំពេញ ។

មាត្រា ២៦ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច នៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវមានវត្តមានអនុវត្តភារកិច្ចរបស់ខ្លួនក្នុងទីស្នាក់ការតែមួយកន្លែងហើយធ្វើការនៅជាប់ៗគ្នា ដើម្បីសំរួលការងារក្នុងការពេញបែបបទដល់អ្នកដំណើរ និងម្ចាស់ទំនិញឱ្យបានឆាប់ ។

មាត្រា ២៧ .-

ប្រធានភ្នាក់ងារ មានសមត្ថកិច្ចជំនាញនីមួយៗ ត្រូវបែងចែកវេនប្រចាំការ តិចទាំងថ្ងៃឈប់សំរាក ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃទីស្នាក់ការ ត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានានិរន្តរភាពការងារ ។

## ជំពូកទី ៧

## សមត្ថកិច្ចអាជ្ញាធរដែនដី

មាត្រា ២៨ .-

អភិបាល ខេត្ត-ក្រុង សាមី តំណាងឱ្យរាជរដ្ឋាភិបាល មានភារកិច្ច :

- ដាក់ចេញ និងត្រួតពិនិត្យការអនុវត្តនីបទបញ្ជាផ្ទៃក្នុងរបស់ទីស្នាក់ការត្រួតពិនិត្យ ដែលស្ថិតក្នុងដែនដីគ្រប់គ្រងរបស់ខ្លួន និងសំរបសំរួលដល់ការងារ ដើម្បីធ្វើឱ្យទីស្នាក់ការត្រួតពិនិត្យមានដំណើរការស្របច្បាប់ និងលិខិតបទបញ្ញត្តិជាធរមាន
- បង្ក្រាប និងលុបបំបាត់កំលាំងដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យ ក្នុងដែនដីគ្រប់គ្រងរបស់ខ្លួន
- ពិនិត្យ និងចុះហត្ថលេខា លើរបាយការណ៍របស់ទីស្នាក់កា/ត្រួតពិនិត្យ ដើម្បីផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៨

## អាណត្តិបំរើការងារ

មាត្រា ២៩ .-

ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ និងប្រធានភ្នាក់ងារមានសមត្ថកិច្ចជំនាញ ត្រូវធ្វើការផ្លាស់ប្តូររយៈពេល ០២ឆ្នាំម្តង ។

មាត្រា ៣០ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ ត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល ០១ឆ្នាំម្តង ។

មាត្រា ៣១ .-

ប្រធានក្រសួង ស្ថាប័ន ជំនាញនីមួយៗ អាចធ្វើការផ្លាស់ប្តូរទៅតាមតម្រូវការចាំបាច់ ចំពោះមន្ត្រីដឹកនាំ និងមន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅតាមទីស្នាក់ការត្រួតពិនិត្យនានានៅពេលណាក៏បាន ។

## ជំពូកទី ៩
## កំលាំងអន្តរាគមន៍

មាត្រា ៣២ .-

កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងនគរបាលជាតិ និងសមត្ថកិច្ចដទៃទៀត ដែលមានទីតាំងនៅជិតទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ត្រូវចេញធ្វើអន្តរាគមន៍ ក្នុងករណីដែលមានសំណើសុំពីប្រធានទីស្នាក់ការត្រួតពិនិត្យ ។

មាត្រា ៣៣ .-

កំលាំងអន្តរាគមន៍ដែលមានចែងក្នុងមាត្រា ៣២ មិនត្រូវមានទីតាំង ឬបន្ទាយ និងមិនត្រូវធ្វើសកម្មភាពក្នុងភូមិសាស្ត្រច្រកទ្វាររបស់ទីស្នាក់ការត្រួតពិនិត្យទេ ក្នុងករណីគ្មានសំណូមពរពីប្រធានទីស្នាក់ការត្រួតពិនិត្យ ។

## ជំពូកទី ១០
## យន្តការឃ្លាំមើល

មាត្រា ៣៤ .-

បង្កើតយន្តការមួយដែលមានតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន តំណាងក្រសួង ស្ថាប័ន និងតំណាងសាលា ខេត្ត-ក្រុង ពាក់ព័ន្ធ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីឃ្លាំមើលសកម្មភាព របស់ទីស្នាក់ការត្រួតពិនិត្យ និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

16

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

មាត្រា ៣៥ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលឆ្លៀតប្រើប្រាស់តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនបង្កឱ្យមានការលំបាកដល់អ្នកដំណើរ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដោយគ្មានមូលហេតុស្របច្បាប់ ឬរំលោភសមត្ថកិច្ច ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៣៦ .-

អាជ្ញាធរដែនដីណា ដែលមិនបានបំពេញភារកិច្ចក្នុងការលុបបំបាត់ឱ្យអស់ជាស្ថាពរនូវកន្លែងត្រួតពិនិត្យអនាធិបតេយ្យ ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន នឹងត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

មាត្រា ៣៧ .-

ទីស្នាក់ការត្រួតពិនិត្យត្រូវមានតែមួយកន្លែងរួមគ្នា សំរាប់ច្រកទ្វារមួយទាំងមូល ។ ក្នុងករណីពុំទាន់មានទីស្នាក់ការត្រួតពិនិត្យរួមតែមួយនៅឡើយទេនោះ មន្ត្រីភ្នាក់ងារមានសមត្ថកិច្ចទាំងអស់ ត្រូវធ្វើការនៅក្នុងទីស្នាក់ការគយ និងរដ្ឋាករ ជាបណ្តោះអាសន្ន រហូតទីស្នាក់ការត្រួតពិនិត្យរួម ត្រូវបានសាងសង់រួចជាស្ថាពរ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

មាត្រា ៣៨ .-

អនុក្រឹត្យលេខ ៤៥អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ អនុក្រឹត្យលេខ ៤៩អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧ លិខិតបញ្ជាលេខ ២២បជ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ អនុក្រឹត្យលេខ ៣៦អនក្រ.បក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨ សេចក្តីសំរេចលេខ ១៨សសរ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

17

មាត្រា ៣៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលគ្រប់ ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៩
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី
## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទ នៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំ រេ ច

ប្រការ ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើង តាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអោយសាលាក្រុងភ្នំពេញធ្វើការទូទាត់ក្នុងការទិញដី រៀបចំលំនៅដ្ឋានប្រជាពលរដ្ឋ នៅភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានទឹកប្រាក់សរុប ចំនួន **USD 150.000,00** ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលក្រុងភ្នំពេញ និង ប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៣៤..ស.សរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ កម្ពុជា - ថៃ

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត អាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពី ការ តែងតាំង សមាសភាពគ្រប់គ្រងដឹកនាំ នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរ ប្រេងកាតជាតិកម្ពុជា

## សំរេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រកម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ:

**១- ឯកឧត្តម សុខ អាន រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា**

ជា ប្រធានកិត្តិយស

២- ឯកឧត្តម បណ្ឌិត ហេង វង្សប៊ុនឆាត, អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជា ឧត្តមទីប្រឹក្សា

៣- ឯកឧត្តម ហូ វិចិត្រ, អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៤- ឯកឧត្តម វ៉ា គឹម ហុង, ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ជា អនុប្រធាន

៥- ឯកឧត្តម តែ ដួង តារា, អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៦- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការសេដ្ឋកិច្ច ជា សមាជិក

៧- តំណាងឧត្តមនាវីឯក អ៊ុង សំខាន់, មេបញ្ជាការកងទ័ពជើងទឹក ជា សមាជិក

៨- លោក ឡេប សារីសិដ្ឋ, ជំនួយការផ្ទាល់ឯកឧត្តម សុខ អាន ជាសមាជិក

៩- លោក ហួន សារ៉ាង, អគ្គនាយករងនៃក្រសួងរៀបចំដែនដី-នគរូបនីយកម្ម និង សំណង់ ជាសមាជិក

១០-លោក ឃួន សុគន្ធា, អនុប្រធាននាយកដ្ឋានទទួលបន្ទុកកិច្ចការច្បាប់ និង ចរចា ជាសមាជិក

**ប្រការ ២.-**

គណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា - ថៃ មានភារៈកិច្ចដូចខាងក្រោម :

(ក) ចរចា-រៀបចំ សន្ធិសញ្ញា និង គ្រប់ប្រព័ន្ធច្បាប់គ្រប់គ្រង-បទបញ្ញត្តិ-គោលការណ៍-បទដ្ឋានទាំងអស់ដែលពាក់ព័ន្ធដល់ ការអភិវឌ្ឍន៍រួមគ្នានៃធនធានប្រេងកាត រាប់បញ្ចូលទាំងមូលដ្ឋានគ្រឹះ ដែលមានផលប្រយោជន៍ទៅវិញទៅមក និង អាចទទួលយកបានដោយភាគីទាំងពីរ ចំពោះការបែងចែកលើ ការចំណាយ

និង ផលចំណេញ នៃការធ្វើអាជីវកម្មលើធនធានអ៊ីដ្រូកាបួរ ដែលឋិតនៅក្នុងតំបន់ នៃ ការអភិវឌ្ឍន៍រួមគ្នា ដើម្បីដាក់ជូន រាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(ខ) ចរចា-រៀបចំ សន្ធិសញ្ញាលើការកំណត់បែងចែកព្រំដែនសមុទ្រផ្ទៃក្នុង, ខ្ពង់រាបបាតសមុទ្រ និង តំបន់ឯកសិទ្ធិសេដ្ឋកិច្ច ដែលឋិតនៅចន្លោះនៃការទាមទារអះអាងដែនសមុទ្រ បច្ចុប្បន្នរៀង១ខ្លួនរបស់ប្រទេសទាំងពីរ នៅក្នុងតំបន់ដែលនឹងត្រូវបែងចែកព្រំដែន អនុលោមទៅតាមបណ្តាគោលការណ៍ ទាំងឡាយដែលអាច អនុវត្តបាន នៃច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(គ) ដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះត្រូវចុះអង្កេត-ផ្ទៀងផ្ទាត់រួមគ្នាលើ និយាមការ ( កូអ័រដោណេ ) នៃកោះ, ថ្ម, ថ្មប៉ប្រះទឹក,ចំណុចនីមួយ១ និង អ្វី១ទាំងអស់ ដែលមានលក្ខណៈពិសេស និង ចរិតប្រវត្តិសាស្ត្រពាក់ព័ន្ធ ឋិតនៅក្នុងដែនដីគោក និង ដែនសមុទ្រ កម្ពុជា - ថៃ ។

ប្រការ ៣.-

គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះ ត្រូវជួបប្រជុំគ្នាអោយបានទៀងទាត់ ក្នុងទស្សនៈសំរេច អោយបាននូវការងាររបស់ខ្លួនទាក់ទងទៅនឹងបញ្ហាទាំងអស់នេះអោយបានឆាប់រួសរាន់ ។ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះ អាចបង្កើតឡើងនូវអនុគណៈកម្មាធិការ ដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ ។

ប្រការ ៤.-

គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចំរុះនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន ហើយគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ នឹងត្រូវរាយការណ៍ ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន ។

ប្រការ ៥.-

គណៈកម្មាធិការបច្ចេកទេសចំរុះនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និង មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ ~**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចំលងជូន៖</u>**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល*

*- ដូចប្រការ ៦*

*-ឯកសារ-កាលប្បវត្តិ*

III.MD.phs.54

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៩ សសរ

# សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ ថាមពល កកើតឡើងវិញ និង បច្ចេកវិទ្យាថាមពល កម្ពុជា-ជប៉ុន

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃជំនួបសំណេះសំណាលនៅតូក្យូ នាថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០១ រវាងសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងលោក ស៊ុយតូមុ៉យ ម៉ាតេណូ ប្រធានអង្គការណេដូ (NEDO)

## សំរេច

ប្រការ ១ : បង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាថាមពល កម្ពុជា-ជប៉ុន ដែលមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | លោកបណ្ឌិត | សាត សាមី | ប្រធាននាយកដ្ឋានថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ប្រធាន |
| ២- | លោកបណ្ឌិត | ជា វ៉ាន់ដេត | ជំនួយការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- | លោក | អ៊ុង សំអាត | អនុប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៤- | លោក | សាត សមុទ្រ | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |

ﾑ

៥- លោក ឆាយ ថៃ មន្ត្រីនៃអគ្គលេខាធិការដ្ឋាន OBSES សមាជិក

**ប្រការ ២ :** ក្រុមការងារនេះ មានបេសកកម្ម ដូចខាងក្រោម:

- ជំរុញលើកទឹកចិត្ត និង ធ្វើអោយប្រសើរឡើង ក្នុងការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ ដោយអនុវត្តនូវបច្ចេកវិទ្យាប្រព័ន្ធថាមពលអគ្គិសនីគំរូ សំរាប់បង្ហាញ ផ្សព្វផ្សាយ ស្រាវជ្រាវ បណ្តុះបណ្តាល និងគ្រប់គ្រងអោយមានប្រសិទ្ធភាពនិងសុវត្ថិភាព ។
- អនុវត្តគំរោង និង តំលើងនូវប្រព័ន្ធថាមពលអគ្គិសនីគំរូ នៅតាមបណ្តាទីតាំងជាអាទិភាព ដូចជា មណ្ឌលសុខភាព មណ្ឌលកុមារកំព្រា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សាលារៀន វត្តអារាម និងភូមិគំរូ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល ដើម្បីរួមចំណែកដល់ការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ថាមពលអគ្គិសនីសំរាប់បំភ្លឺ បូមទឹកស្អាត ថែរក្សាវ៉ាក់សាំង ប្រើប្រាស់កុំព្យូទ័រ ប្រព័ន្ធទំនាក់ទំនង វិទ្យុ និងទូរទស្សន៍ ។ល។
- ធ្វើការអង្កេត ប្រមូលទិន្នន័យ សិក្សាស្រាវជ្រាវ វិភាគ វាយតំលៃ សំរាប់កសាងផែនការមេ លើវិស័យថាមពលកកើតឡើងវិញ និងព្រមទាំងកំណត់នូវសក្តានុពលនៃធនធាននីមួយៗ អោយបានច្បាស់លាស់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេសកម្ពុជា ។
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី ដោយធ្វើការផ្លាស់ប្តូរបទពិសោធន៍នូវពត៌មានវិទ្យា-បច្ចេកវិទ្យា និង ប្រមូលចងក្រងឯកសារ ដើម្បីជាមូលដ្ឋានគ្រឹះ និងជាទិសដៅឆ្ពោះទៅដល់ការផ្តល់ អនុសាសន៍លើការរៀបចំយុទ្ធសាស្ត្រ គោលការណ៍ គោលនយោបាយ និង ផែនការសកម្មភាពរយៈពេលខ្លី-មធ្យម-វែង លើវិស័យថាមពលកកើតឡើងវិញ ដោយធានាបាននូវការថែរក្សាបរិស្ថាន ។
- ផ្សព្វផ្សាយ និងរៀបចំគោលនយោបាយអោយមានការលើកទឹកចិត្ត ដល់ការចូលរួមបន្ថែមទៀត ពីសំណាក់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ រួមទាំងផ្នែកឯកជនផងដែរ ។

**ប្រការ ៣:** ដើម្បីបំពេញបេសកកម្មខាងលើ ក្រុមការងារនេះមានភារកិច្ច និងតួនាទី :

- សំរបសំរួល និង សហការជាមួយអង្គការណេដូ (New Energy and Industrial Technology Development Organization, NEDO) ប្រទេសជប៉ុន ដើម្បីជំរុញការសិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងប្រើប្រាស់នូវបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- សំរបសំរួល និង សហការជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចខេត្ត-ក្រុងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ក្រុមហ៊ុនឯកជន ដើម្បីជំរុញការអនុវត្តនិងការអភិវឌ្ឍ អោយមានប្រសិទ្ធភាព សុវត្ថិភាព ក្នុងអត្ថន័យការពារបរិស្ថាន ។
- ចូលរួមប្រជុំ និង ធ្វើទំនាក់ទំនងផ្ទាល់ ជាមួយអង្គការណេដូ ក៏ដូចជាអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ លើវិស័យថាមពលកកើតឡើងវិញ និង ផ្នែកបច្ចេកវិទ្យាថាមពល ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍សំរេច ។

**ប្រការ ៤:** សមាជិកក្រុមការងារខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន។ ក្នុងករណីសមាជិកណាម្នាក់មិនបានអញ្ជើញចូលរួមប្រជុំ ដោយជាប់រវល់ភារៈកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេចអោយចូលរួមជំនួស។

**ប្រការ ៥:** ក្រុមការងារនេះ មានលេខាធិការដ្ឋានមួយប្រចាំនៅទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ព្រមទាំងបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអោយមានប្រសិទ្ធភាពនូវសេចក្តីសំរេចនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

__ចំលងជូន__

- *-ក្រសួងព្រះបរមរាជវាំង*
- *-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *-ដូចប្រការ ៦ "ដើម្បីអនុវត្ត"*
- *-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :......៤០......សសរ.**

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវធាតុភាពផ្ទុះគ្រាប់បែក នៅសណ្ឋាគារ ហុង កុង និងសណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត )

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវធាតុភាពករណីដាក់អោយផ្ទុះគ្រាប់បែកនៅសណ្ឋាគារ ហុង កុង និងសណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត ) កាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១ ដូចមានសមាសភាព រាយនាមខាងក្រោម ÷

១- ឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ ជាប្រធាន

២- ឯកឧត្តម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាអនុប្រធាន

៣- ឯកឧត្តម អ៊ី ជន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាសមាជិក

៤- ឯកឧត្តម មល់ រឿប ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

៥- ឯកឧត្តម យូ ស៊ិនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

៦- ឯកឧត្តម នេត សាវឿន ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ជាសមាជិក

៧- លោកឧត្តមសេនីយ៍ត្រី សុខ ផល ប្រធាននាយកដ្ឋានពត៌មានទូទៅ ជាសមាជិក

៨- លោកឧត្តមសេនីយ៍ត្រី វង្ស ពិសេន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ ជាសមាជិក

៩- លោកឧត្តមសេនីយ៍ត្រី សួន ឈាងលី ស្នងការនគរបាលរាជធានីភ្នំពេញ ជាសមាជិក

**ប្រការ ២:** គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

- ស្រាវជ្រាវគ្រប់មូលហេតុអោយបានហ្មត់ចត់ ដែលកើតមានឡើងចំពោះករណីការដាក់អោយផ្ទុះគ្រាប់បែក នៅសណ្ឋាគារ ហុង កុង និង សណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត ) កាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១ កន្លងមក ។
- គណៈកម្មការនេះមានសិទ្ធិកោះអញ្ជើញគ្រប់សមាសភាពដែលពាក់ព័ន្ធមកបំភ្លឺ ។
- រាយការណ៍ពីលទ្ធផលជូននាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ស ខេង ដើម្បីពិនិត្យ និងសំរេច ។
- គណកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋាននគរបាលជាតិ ។
- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធករណីខាងលើ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០១

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៧២ សហវ.ប្រ.

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០១

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារចំរុះអន្តរក្រសួង ដើម្បីពិនិត្យកិច្ចសន្យាលក់ឬជួលចលនវត្ថុឬអចលនវត្ថុ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងប្រមូលចំណូលបង់ចូលថវិការដ្ឋ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២នស/រកត/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ ១៦៨៩ សហវ.ឧរ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញសេចក្តីជូនដំណឹងលេខ ០១០ សហវ.ឧរ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ ៩៣៩ ដនស-ផសហ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញតំរូវការចាំបាច់របស់ក្រសួង

## សំរេច

ប្រការ១ : តែងតាំង :

១-លោក នេត មុន្នី អនុប្រធានប្រធានទី១ នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ ប្រធាន

២-លោក តាន់ សេងហៀង អនុប្រធាននាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច
នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៣-លោកស្រី សូនពិន កាន្និកា មន្ត្រីការិយាល័យសង្ហារិម និងអសង្ហារិម នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៤-លោកស្រី ភួយ ចាន់ធី មន្ត្រីការិយាល័យសង្ហារិម និងអសង្ហារិម នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៥-លោក ហាក់ ហ៊ុន មន្ត្រីការិយាល័យគណនេយ្យនៃនាយកដ្ឋានផែនការ សេដ្ឋកិច្ចនិងហិរញ្ញកិច្ច
នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

ប្រការ២ : រាល់លទ្ធផលការងារដែលទទួលបាន ក្រុមការងារចំរុះអន្តរក្រសួងនេះត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យសំរេច ។

ប្រការ៣ : អគ្គលេខាធិការដ្ឋាន ខុទ្ទកាល័យ និងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ចនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ព្រមទាំងក្រុមការងារចំរុះអន្តរក្រសួងដូចប្រការ១ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ដូចប្រការ៣
- ដូចប្រការ ១ ដើម្បីអនុវត្ត
- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៣៧៩ សហវ.

រាជធានីភ្នំពេញ . ថ្ងៃ ទី ១២ ខែ កក្កដា ឆ្នាំ ២០០១

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវង្វេទយ្យបុរេប្រទាននៅ ផ្នែកអប់រំ
## នៃ ក្រសួងអប់រំ យុវជន និង កីឡា

## ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សី ហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រ កម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ :០២ នស .៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ -

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ន.សចុះថ្ងៃទី២៨ខែធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១.នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/ រកម/ ១២៩៩/១៥ ចុះថ្ងៃទី២៥ខែធ្នូ ឆ្នាំ ១៩៩៩ ។

-បានឃើញ ព្រះរាជក្រម នស/ រកម/ ១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ខែវិច្ឆិកា ឆ្នាំ១៩៩៥ស្តីពីបទបញ្ញាទូទៅ នៃគណ នេយ្យសាធារណៈ។

-បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅនៃ គណនេយ្យសាធារណៈ ។

-បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅ នៃគណនេយ្យ សាធារណៈ ។

-បានឃើញសារាចរណែនាំលេខ: ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី រជ្ជទេយ្យ បុរេប្រទាន ។

-បានឃើញប្រកាសលេខ ១២៩ ប្រក. សហវចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ១៩៩៧ ស្តីពីការកំនត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន

ជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ ទៅលើដំណើរការរដ្ឋបាលសំភារៈនិងជួសជុល តូច ។

-បានឃើញ តម្រូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន ។

## សំរេច

ប្រការ ១: ត្រូវបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ១១ នៅក្រសួងអប់រំយុវជន និងកីឡា (ផ្នែកអប់រំ) ដើម្បីទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យលេខ:៨២ អនក្រ.បក ចុះថ្ងៃទី១៦ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃ គណនេយ្យ សាធារណៈ។ចំនួនទឹកប្រាក់ ជាអតិបរិមានៃ ចំណាយដែលអនុញ្ញាត អោយរជ្ជទេយ្យករបុរេប្រទាន ធ្វើការទូទាត់ ត្រូវ កំណត់កំរិតក្រោម ៥០០,០០០៛០០ (ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយនិមួយៗ ដូចមានចែងក្នុងតារាង ឧបសម្ព័ន្ធ ភ្ជាប់ជាមួយ ប្រកាស អន្តរក្រសួង ។

ប្រការ ២: ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានជំពូក១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹម ចំនួន ២៦៤,០០០,០០០៛០០ ( ពីររយហុកសិបបួនលាន រៀល គត់ ) ។

ប្រការ ៣: សេចក្ដីសំរេចទាំងឡាយណា ដែលមាន ខ្លឹមសារផ្ទុយ នឹង ប្រកាស នេះ ត្រូវទុក ជា និរាករណ៍ ។

